ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៅក្នុងអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសាលដីកាស្ថាពររបស់តុលាការកំពូល នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកាត់ទោសរំលាយគណបក្សសង្គ្រោះជាតិ និងហាមឃាត់ធ្វើសកម្មភាពនយោបាយ រយៈពេល ០៥ឆ្នាំ ចំពោះថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន ១១៨រូប គឺពិតជាត្រឹមត្រូវយុត្តិធម៌បំផុតទៅនឹងទង្វើក្បត់ជាតិរបស់គណបក្សនេះ ដែលមិនអាចអត់ឱនលើកលែងឲ្យបានឡើយ ។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រចំពោះវិធានការច្បាប់របស់តុលាការ និងសូមគោរពអនុវត្តម៉ឺងម៉ាត់តាមបទបញ្ជារបស់ក្រសួងការពារជាតិ ជាពិសេសត្រៀមអនុវត្តបទបញ្ជាគ្រប់កាលៈទេសៈ ចំពោះវិធានការបន្តដែលដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់ស្កាត់ឧបាយកលពិសពុលនៃបដិវត្តន៍ពណ៌នៅកម្ពុជា ប្រឆាំងដាច់ខាត់រាល់ល្បិចកលរបស់ក្រុមអ្នកនយោបាយ និងជនអគតិមួយចំនួនដែលឃុបឃិតនិងបម្រើផលប្រយោជន៍បរទេស ។ ប្តេជ្ញាការពារបូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងនិងការជ្រៀតជ្រែកទាំងឡាយរបស់បរទេស ។

សូមគាំទ្រឲ្យមានការចាត់វិធានការផ្លូវច្បាប់ជាបន្តបន្ទាប់ទៀតឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ ភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនរុងរឿងតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គនាយក**

នាយឧត្តមសេនីយ៍ **ស៊ុំ សំណាង**